ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយវេជ្ជសាស្ត្របុរាណ នៃព្រះរាជាណាចក្រកម្ពុជា

ក្រសួងសុខាភិបាល

ឧបត្ថម្ភដោយ: អង្គការសុខភាពពិភពលោក

# អារម្ភកថា

ការរៀបចំនិងអនុវត្តគោលនយោបាយវេជ្ជសាស្ត្របុរាណនៅព្រះរាជាណាចក្រកម្ពុជាគឺជាការសម្របសម្រួលវិស័យសុខាភិបាល និងជាការឆ្លើយតបទៅតាមការវិវឌ្ឍរីកចម្រើននៃសង្គម សេដ្ឋកិច្ច បច្ចេកវិទ្យា និងនយោបាយរបស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណ និងកោតសរសើរ ចំពោះរាល់ការខិតខំប្រឹងប្រែងទាំងឡាយរបស់មន្ត្រីនៃក្រសួងសុខាភិបាល ក៏ដូចជាអង្គការសុខភាពពិភពលោកដែលបានជួយរួមគ្នាតាក់តែងគោលនយោបាយដ៏មានសារៈសំខាន់នេះ។

វាជាការពិតណាស់ថា វេជ្ជសាស្ត្របុរាណនៃព្រះរាជាណាចក្រកម្ពុជាមានប្រវត្តិសម្បូរបែប ជាផ្នែកសំខាន់ក្នុងការលើកកំពស់សុខភាព និងការព្យាបាលប្រជាពលរដ្ឋតាំងពីយូរលង់មកហើយ ។ ភាពសម្បូរបែបនៃជីវៈចម្រុះតំបន់ត្រូពិកនៅកម្ពុជាជាប្រភពធម្មជាតិដ៏មានសក្តានុពលក្នុងការលើកកំពស់វិស័យវេជ្ជសាស្ត្រនិងឱសថសាស្ត្របុរាណ។ បច្ចុប្បន្នប្រជាពលរដ្ឋភាគច្រើន ពិសេសនៅតាមទីជនបទ តែងពឹងអាស្រ័យលើឱសថបុរាណ។

វេជ្ជសាស្ត្របុរាណ ក៏ដូចជាវេជ្ជសាស្ត្រសម័យដែរ ត្រូវតែមានទស្សនវិជ្ជាដូចគ្នាក្នុងការជួយកំចាត់ការឈឺចាប់ ការពារ-ព្យាបាលជំងឺ និងជួយដល់សុខភាពប្រជាពលរដ្ឋប្រកបដោយគុណធម៌។ ការប្រើប្រាស់ប្រជាប្រិយភាពរបស់វេជ្ជសាស្ត្របុរាណក្នុងការប្រណាំងប្រជែងគ្នាបែបអាជីវកម្ម សេវាកម្មធម្មតា ជាទង្វើផ្ទុយពីទស្សនវិជ្ជានិងគុណធម៌ខាងលើនេះ។

ក្រសួងសុខាភិបាលមានគោលដៅបញ្ជ្រៀតវេជ្ជសាស្ត្របុរាណចូលក្នុងប្រព័ន្ធថែទាំសុខភាពជាតិ និងជាផ្នែកមួយនៃប្រព័ន្ធថែទាំសុខភាពបឋម។ ក្នុងនោះ មានកម្មវិធីជាច្រើនដែលត្រូវបំពេញដូចជា ការអភិរក្សនិងអភិវឌ្ឍរុក្ខជាតិឱសថ ការអប់រំបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ ការលើកកំពស់គុណភាពផលិតផល...។

ឯកសារនេះផ្តល់នូវគោលនយោបាយដំបូងបង្អស់ដែលមានលក្ខណៈទូលំទូលាយ បង្ហាញនូវគំនិតផ្តួចផ្តើមតាក់តែងបន្ថែមនូវបទប្បញ្ញត្តិ និងចំណុចចំបងៗដែលត្រូវយកចិត្តទុកដាក់ដើម្បីធ្វើយ៉ាងណាឲ្យប្រជាជនកម្ពុជាទទួលបានផលប្រយោជន៍ពីវេជ្ជសាស្ត្រ - ឱសថសាស្ត្របុរាណ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាព។

ខ្ញុំសូមអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ មេត្តាផ្តល់នូវការឧបត្ថម្ភគាំទ្រ និងស្វែងយល់អំពីគោលនយោបាយដ៏មានសារៈសំខាន់នេះ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ តុលា ឆ្នាំ ២០១០

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង

# គោលនយោបាយវេជ្ជសាស្ត្របុរាណ
# នៃព្រះរាជាណាចក្រកម្ពុជា

## មាតិកា


អារម្ភកថា..........១

មាតិកា..........៣

សេចក្តីថ្លែងអំណរគុណ..........៥

១- សេចក្តីផ្តើម..........៦

២- និយមន័យ..........៦

២.១- វេជ្ជសាស្ត្របុរាណ..........៦

២.២ - ឱសថបុរាណ..........៧

៣- សេចក្តីថ្លែងការណ៍នៃគោលនយោបាយវេជ្ជសាស្ត្របុរាណនៃព្រះរាជាណាចក្រកម្ពុជា..........៧

៤- ទស្សនវិស័យ បេសកកម្មនិងគោលបំណងនៃគោលនយោបាយវេជ្ជសាស្ត្របុរាណ..........៧

៤.១ - ទស្សនវិស័យ..........៧

៤.២- បេសកកម្ម..........៧

៤.៣- គោលបំណង..........៧

៥- យុទ្ធសាស្ត្រនៃគោលនយោបាយវេជ្ជសាស្ត្របុរាណ..........៨

៥.១- វិជ្ជាជីវៈវេជ្ជសាស្ត្របុរាណ..........៨

៥.២- ការអប់រំនិងបណ្តុះបណ្តាល..........៩

៥.៣- វត្ថុធាតុដើមនិងផលិតផល..........៩

៥.៤- ការសិក្សាស្រាវជ្រាវ..........៩

៥.៥-សហប្រតិបត្តិការជាតិនិងអន្តរជាតិ..........១០

៥.៦-ការត្រួតពិនិត្យនិងវាយតម្លៃ..........១០

# សេចក្តីថ្លែងអំណរគុណ

គោលនយោបាយវេជ្ជសាស្ត្របុរាណនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានរៀបចំដោយក្រសួងសុខាភិបាល និងបានការជួយឧបត្ថម្ភគាំទ្រពីអង្គការសុខភាពពិភពលោក ។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណ ចំពោះគណៈកម្មការចងក្រងគោលនយោបាយវេជ្ជសាស្ត្របុរាណនៃព្រះរាជាណាចក្រកម្ពុជាដែលមានរាយនាមដូចខាងក្រោមៈ

| | | |
|---|---|---|
| ១-លោកជំទាវបណ្ឌិត | **អ៊ុក ម៉ុណ្ណា** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ២-ឯកឧត្តម | **ជូ យិនស៊ីម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៣-ឯកឧត្តម | **យឹម យ៉ាន់** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៤-ឯកឧត្តម | **ឆេង លន់** | អគ្គនាយកបច្ចេកទេសសុខាភិបាល |
| ៥-លោកវេជ្ជ | **ភូ លាង** | អគ្គនាយករងបច្ចេកទេសសុខាភិបាល |
| ៦-លោកវេជ្ជ. | **ហ៊ាង ពន្លៃ** | ប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ |
| ៧-លោកសាស្ត្រាចារ្យ | **David Briggs** | អ្នកឯកទេសសរសេរគោលនយោបាយ WHO |
| ៨-លោកស្រីសាស្ត្រាចារ្យ | **Narantuya Samdan** | ទីប្រឹក្សា WHO ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក |
| ៩-លោក | **William M fuko** | តំណាងអង្គការសុខភាពពិភពលោកនៅកម្ពុជា |
| ១០-លោកវេជ្ជ. | **ឆាយ ស៊ីផុន** | អនុប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ |
| ១១-លោកស្រីឱ.ការី | **អ៊ឹង សុខលាន** | អនុប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ |
| ១២- លោកឱ.ការី | **ទឹង យឹមហ៊ាង** | អនុប្រធាននាយកដ្ឋានឱសថ |
| ១៣-លោកឱ.ការី | **ឈៀង ផាន់ណា** | អនុប្រធាននាយកដ្ឋានឱសថ |
| ១៤-លោកវេជ្ជ. | **ប៊ុល ស៊ីវត្ថា** | ប្រធានការិយាល័យបច្ចេកទេសនៃមជ្ឈ.វេជ្ជសាស្ត្របុរាណ |
| ១៥-លោកអនុបណ្ឌិត | **ម៉ៅ សុខលីម** | ប្រធានការិយាល័យរដ្ឋបាល នៃមជ្ឈ.វេជ្ជសាស្ត្របុរាណ |
| ១៦-លោកស្រីឱ.ការី | **នៅ ផល្លា** | ប្រធានការិយាល័យបញ្ជិកាឱសថ |
| ១៧-លោកវេជ្ជ. | **ប៊ូ កែវចិន្តា** | អនុប្រធានការិយាល័យបច្ចេកទេសនៃមជ្ឈ.វេជ្ជសាស្ត្របុរាណ |
| ១៨-លោក | **លឹម ឆេន** | អនុប្រ.ការិយាល័យរដ្ឋបាលនៃមជ្ឈ.វេជ្ជសាស្ត្របុរាណ |
| ១៩-លោកឱ.បណ្ឌិត | **ប៉ែន ស៊ុនណា** | មន្ត្រីការិយាល័យបច្ចេកទេសនៃមជ្ឈ.វេជ្ជសាស្ត្របុរាណ |
| ២០-លោកស្រីវេជ្ជ. | **ហ៊ូ ហែមមុណ្ណារី** | មន្ត្រីការិយាល័យបច្ចេកទេសនៃមជ្ឈ.វេជ្ជសាស្ត្របុរាណ |
| ២១-លោកស្រីវេជ្ជ. | **សុខសូរតនា** | មន្ត្រីការិយាល័យរដ្ឋបាល នៃមជ្ឈ.វេជ្ជសាស្ត្របុរាណ |
| ២២-លោកវេជ្ជ | **គង់ សុខឌីណា** | មន្ត្រីការិយាល័យបច្ចេកទេសនៃមជ្ឈ.វេជ្ជសាស្ត្របុរាណ |

## ១- សេចក្តីផ្តើម

គោលនយោបាយវេជ្ជសាស្ត្របុរាណនៃព្រះរាជាណាចក្រកម្ពុជាប្រើសម្រាប់ជាឯកសារយោង ដើម្បីណែនាំការអនុវត្តនិងគ្រប់គ្រងវេជ្ជសាស្ត្របុរាណនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលនយោបាយនេះមានវិសាលភាពលើការអនុវត្តការអប់រំបណ្តុះបណ្តាល ការធ្វើបទប្បញ្ញត្តិ ការស្រាវជ្រាវ និងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិទាក់ទងនឹងវេជ្ជសាស្ត្រ ឱសថសាស្ត្របុរាណ។ វេជ្ជសាស្ត្របុរាណនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានប្រភពសម្បូរបែប ដែលស្តែងឡើងដោយការនិយាយផ្ទាល់មាត់ ឬ ការសរសេរចងក្រងអំពីចំណេះដឹងផ្នែកវេជ្ជសាស្ត្រ។ បើទោះបីមានការកត់សម្គាល់ តិចតួចពីប្រភព វេជ្ជសាស្ត្របុរាណក្តីក៏ភស្តុតាងបានបង្ហាញថា វេជ្ជសាស្ត្របុរាណរបស់ខ្មែរដើមបានវិវឌ្ឍឡើងខ្ពស់នៅក្នុងសម័យអង្គរ( សតវត្សទី៩-១៥នៃគ្រិស្តសករាជ)។ ប្រភពដើមទាំងនេះបានយកតាមលំនាំជំនឿក្នុងស្រុកមកបង្កើតជាប្រព័ន្ធវេជ្ជសាស្ត្របុរាណនៅក្នុងតំបន់។ ការប្រើប្រាស់ចំណេះដឹងដ៏ប្រសើរនេះ ជាឱកាសដ៏មានសារៈសំខាន់ចំពោះការថែទាំសុខភាពបឋម និងការទទួលបាននូវ សុវត្ថិភាពនិងប្រសិទ្ធភាពក្នុងការព្យាបាល។

វេជ្ជសាស្ត្របុរាណក៏ជាផ្នែកសំខាន់សម្រាប់ការការពារការលើកកំពស់សុខភាព និងការព្យាបាលក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយមានប្រវត្តិតាំងពីយូរលង់ណាស់មកហើយ ប្រជាពលរដ្ឋភាគច្រើនបានចាប់អារម្មណ៍ទៅលើទំនៀមទម្លាប់ ប្រពៃណីផ្ទាល់ខ្លួននិងជំនឿលើឱសថបុរាណ ដែលឆ្លើយតបទៅតាមតម្រូវការថែទាំសុខភាពរបស់ខ្លួន។ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ជនបទ និងតំបន់ឆ្ងាយដាច់ស្រយាល តែងតែប្រើឱសថដែលងាយរកបានក្នុងមូលដ្ឋាន សម្រាប់ការពារ ឬព្យាបាលជំងឺទូទៅនិងអាការៈផ្សេងៗ។ភាពសម្បូរបែបនៃជីវៈចម្រុះនៃតំបន់ត្រូពិកនៅព្រះរាជាណាចក្រកម្ពុជា ជាប្រភពធម្មជាតិដ៏មានសក្តានុពលនិងមានតម្លៃចំពោះសុខភាព ដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងលើកកំពស់។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាគាំទ្រវេជ្ជសាស្ត្របុរាណ កំណត់យន្តការដើម្បីអនុវត្តគោលនយោបាយមួយដោយមានការវាយតម្លៃតាមតំណាក់កាលនិមួយៗ និងធ្វើសមាហរណកម្មក្នុងប្រព័ន្ធសុខាភិបាលជាតិ។

## ២- និយមន័យ

### ២.១- វេជ្ជសាស្ត្របុរាណ

ជាបណ្តុំចំណេះដឹងជំនាញ និងការអនុវត្តការថែទាំសុខភាព ដែលនិយមតៗគ្នានិងត្រូវបានសហគមន៍ទទួលស្គាល់ក្នុងតួនាទីថែទាំសុខភាពនិងព្យាបាលជំងឺ។ វេជ្ជសាស្ត្របុរាណតែងតែផ្អែកលើ ទ្រឹស្តីជំនឿនិងបទពិសោធន៍បែបអន្តោគ្រាម តាមវប្បធម៌ខុសៗគ្នា និងត្រូវបានអភិវឌ្ឍបន្តពីជំនាន់មួយទៅជំនាន់ មួយទៀត។

### ២.២ - ឱសថបុរាណ

ជាផលិតផលដែលមានប្រភពពីធម្មជាតិ រុក្ខជាតិ សត្វនិងរ៉ែ ដែលមានវត្ថុធាតុដើមមួយមុខឬផ្សំច្រើនមុខ ឬជាគ្រឿងផ្សំដែលបានកែឆ្នៃសម្រាប់ព្យាបាល និងប្រើជាប្រយោជន៍ដល់សុខភាព។ និយមន័យនេះមិនរាប់បញ្ចូលវត្ថុធាតុណាដែលសារធាតុសកម្មត្រូវបានបំបែកចេញ ឬបានពីការធ្វើសំយោគ ឬសម្រឹតសម្រាំងតាមវិធីដែលមិនមែនជាបែបបុរាណ។

## ៣- សេចក្តីថ្លែងការណ៍នៃគោលនយោបាយវេជ្ជសាស្ត្របុរាណនៃព្រះរាជាណាចក្រកម្ពុជា

វេជ្ជសាស្ត្របុរាណនឹងត្រូវក្លាយទៅជាផ្នែកដែលមានសារៈសំខាន់ក្នុងវិស័យសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ វេជ្ជសាស្ត្របុរាណនឹងត្រូវដំណើរការជាមួយវេជ្ជសាស្ត្រសម័យ និងចូលរួមចំណែកក្នុងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

រាជរដ្ឋាភិបាលសម្របសម្រួលការអនុវត្តគោលនយោបាយវេជ្ជសាស្ត្របុរាណ និងផ្តល់ឲ្យមានជាបទវិធានសំដៅលើកកំពស់គុណភាព សុវត្ថិភាព និងប្រសិទ្ធភាពនៃវិជ្ជាជីវៈវេជ្ជសាស្ត្របុរាណនិងឱសថបុរាណ។ គោលនយោបាយវេជ្ជសាស្ត្របុរាណ រួមជាមួយគោលនយោបាយជាតិទូទៅស្តីពីឱសថ មានគោលបំណងបំពេញបន្ថែមនូវតម្រូវការជាក់ស្តែងក្នុងសហគមន៍ដោយឈរលើមូលដ្ឋានពិតប្រាកដ(Evidence Base) នៃសារធាតុក្នុងការបង្ការ និងព្យាបាលជំងឺ។

## ៤- ទស្សនវិស័យ បេសកកម្មនិងគោលបំណងនៃគោលនយោបាយវេជ្ជសាស្ត្របុរាណ

### ៤.១ - ទស្សនវិស័យ

រក្សា និងលើកកំពស់សុខភាពប្រជាពលរដ្ឋឲ្យប្រសើរឡើង ពិសេសប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល តាមរយៈការធ្វើឲ្យសេវាវេជ្ជសាស្ត្របុរាណនិងឱសថបុរាណត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវប្រកបដោយតម្លៃសមស្រប គុណភាព សុវត្ថិភាព និងប្រសិទ្ធភាព។

### ៤.២- បេសកកម្ម

ធានានូវគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពនៃការអនុវត្តវេជ្ជសាស្ត្របុរាណ និងឱសថបុរាណជូនដល់ប្រជាពលរដ្ឋតាមរយៈប្រព័ន្ធសុខាភិបាលជាតិ។

### ៤.៣- គោលបំណង

គោលនយោបាយវេជ្ជសាស្ត្របុរាណមានគោលបំណងដូចខាងក្រោម៖

៤.៣.១- លើកកំពស់វិជ្ជាជីវៈវេជ្ជសាស្ត្របុរាណ ជាគុណប្រយោជន៍សម្រាប់វិស័យសុខាភិបាល សង្គម និងសេដ្ឋកិច្ច ដោយផ្តោតការយកចិត្តទុកដាក់ទៅលើ៖

- ការអភិវឌ្ឍបន្ថែមផ្នែកនីតិក្រម បទវិធាន ក្រមសីលធម៌
- វិចារណកម្មនៃការប្រើប្រាស់ឱសថបុរាណ
- សមាហរណកម្មវិស័យវេជ្ជសាស្ត្របុរាណក្នុងប្រព័ន្ធថែទាំសុខភាពជាតិ

៤.៣.២- អនុវត្តការបណ្តុះបណ្តាលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធឆ្លើយតបនឹងការវិវឌ្ឍឈានឡើង នៅក្នុងប្រទេស ក៏ដូចជានៅក្នុងតំបន់។

៤.៣.៣- យកចិត្តទុកដាក់ចំពោះវត្ថុធាតុដើមនិងផលិតផលៈ

- អភិរក្សនិងអភិវឌ្ឍធនធានធម្មជាតិនិងជីវៈចម្រុះក្នុងប្រទេសដើម្បីធានានូវសក្តានុពល និង និរន្តរភាពនៃសេចក្តីត្រូវការខាងវត្ថុធាតុដើម និងផលិតផលឱសថបុរាណ។
- គ្រប់គ្រងការផលិតនិងការចែកចាយឱសថបុរាណសំដៅធានាគុណភាព ប្រសិទ្ធភាព និង សុវត្ថិភាពស្របតាមនិយាមដែលបានកំណត់និងដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ។

៤.៣.៤- គាំទ្រនិងលើកទឹកចិត្តចំពោះការសិក្សាស្រាវជ្រាវ ការចែកចាយព័ត៌មាននិងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ

៤.៣.៥- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយនេះតាមដំណាក់កាលនិមួយៗ ។

## ៥- យុទ្ធសាស្ត្រនៃគោលនយោបាយវេជ្ជសាស្ត្របុរាណ

ដើម្បីទទួលបានលទ្ធផលស្របតាមគោលបំណងខាងលើ ត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោមៈ

### ៥.១- វិជ្ជាជីវៈវេជ្ជសាស្ត្របុរាណ ៖

៥.១.១- អភិវឌ្ឍបទវិធានវិជ្ជាជីវៈការចុះបញ្ជីសេវាកម្មអាជីវកម្មវេជ្ជសាស្ត្របុរាណបទវិធានវត្ថុធាតុដើម ផលិត ផលពាក់កណ្តាលសម្រេច និងផលិតផលសម្រេចនៃឱសថបុរាណ។

៥.១.២- អភិវឌ្ឍកម្រិតយល់ដឹងខាងមុខវិជ្ជាជីវៈវេជ្ជសាស្ត្របុរាណ តាមរយៈការបណ្តុះបណ្តាលដោយមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

៥.១.៣-គ្រប់គ្រងស្ថិតិអ្នកផ្តល់សេវាវេជ្ជសាស្ត្របុរាណនិងលក់ឱសថបុរាណទោះក្នុងរូបភាពណាក៏ដោយ

៥.១.៤-សមាគមគ្រូឱសថបុរាណ និងអង្គការដែលធ្វើសកម្មភាពទាក់ទងវេជ្ជសាស្ត្របុរាណ និងឱសថបុរាណត្រូវយកចិត្តទុកដាក់ចំពោះលក្ខខណ្ឌនិងគុណភាពសមាជិកសមាគម ជួយជំរុញការអនុវត្តច្បាប់ លិខិតបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈប្រឆាំងនឹងអំពើបោកប្រាស់បន្លំដែលនាំឲ្យប៉ះពាល់ដល់សុខភាព និងអាយុជីវិតប្រជាពលរដ្ឋ។

៥.១.៥- រិះរកមធ្យោបាយដើម្បីធ្វើសមាហរណកម្មវេជ្ជសាស្ត្របុរាណទៅក្នុងប្រព័ន្ធថែទាំសុខភាពបឋម។

- ការអភិវឌ្ឍបន្ថែមផ្នែកនីតិក្រម បទវិធាន ក្រមសីលធម៌
- វិចារណកម្មនៃការប្រើប្រាស់ឱសថបុរាណ
- សមាហរណកម្មវិស័យវេជ្ជសាស្ត្របុរាណក្នុងប្រព័ន្ធថែទាំសុខភាពជាតិ

៤.៣.២- អនុវត្តការបណ្តុះបណ្តាលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធឆ្លើយតបនឹងការរីកវឌ្ឍឈានឡើង នៅក្នុងប្រទេស ក៏ដូចជានៅក្នុងតំបន់។

៤.៣.៣- យកចិត្តទុកដាក់ចំពោះវត្ថុធាតុដើមនិងផលិតផលៈ

- អភិរក្សនិងអភិវឌ្ឍធនធានធម្មជាតិនិងជីវៈចម្រុះក្នុងប្រទេសដើម្បីធានានូវសក្តានុពល និង និរន្តរភាពនៃសេចក្តីត្រូវការខាងវត្ថុធាតុដើម និងផលិតផលឱសថបុរាណ។
- គ្រប់គ្រងការផលិតនិងការចែកចាយឱសថបុរាណសំដៅធានាគុណភាព ប្រសិទ្ធភាព និង សុវត្ថិភាពស្របតាមនិយាមដែលបានកំណត់និងដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ។

៤.៣.៤- គាំទ្រនិងលើកទឹកចិត្តចំពោះការសិក្សាស្រាវជ្រាវ ការចែកចាយព័ត៌មាននិងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ

៤.៣.៥- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយនេះតាមដំណាក់កាលនិមួយៗ ។

## ៥- យុទ្ធសាស្ត្រនៃគោលនយោបាយវេជ្ជសាស្ត្របុរាណ

ដើម្បីទទួលបានលទ្ធផលស្របតាមគោលបំណងខាងលើ ត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោមៈ

### ៥.១- វិជ្ជាជីវៈវេជ្ជសាស្ត្របុរាណ ៖

៥.១.១- អភិវឌ្ឍបទវិធានវិជ្ជាជីវៈការចុះបញ្ជីសេវាកម្មអាជីវកម្មវេជ្ជសាស្ត្របុរាណបទវិធានវត្ថុធាតុដើម ផលិត ផលពាក់កណ្តាលសម្រេច និងផលិតផលសម្រេចនៃឱសថបុរាណ។

៥.១.២- អភិវឌ្ឍកម្រិតយល់ដឹងខាងមុខវិជ្ជាជីវៈវេជ្ជសាស្ត្របុរាណ តាមរយៈការបណ្តុះបណ្តាលដោយមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

៥.១.៣-គ្រប់គ្រងស្ថិតិអ្នកផ្តល់សេវាវេជ្ជសាស្ត្របុរាណនិងលក់ឱសថបុរាណទោះក្នុងរូបភាពណាក៏ដោយ

៥.១.៤-សមាគមគ្រូឱសថបុរាណ និងអង្គការដែលធ្វើសកម្មភាពទាក់ទងវេជ្ជសាស្ត្របុរាណ និងឱសថបុរាណ ត្រូវយកចិត្តទុកដាក់ចំពោះលក្ខខណ្ឌនិងគុណភាពសមាជិកសមាគម ជួយជំរុញការអនុវត្តច្បាប់ លិខិតបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈប្រឆាំងនឹងអំពើបោកប្រាស់បន្លំដែលនាំឲ្យប៉ះពាល់ដល់សុខភាព និងអាយុជីវិតប្រជាពលរដ្ឋ។

៥.១.៥- រិះរកមធ្យោបាយដើម្បីធ្វើសមាហរណកម្មវេជ្ជសាស្ត្របុរាណទៅក្នុងប្រព័ន្ធថែទាំសុខភាពបឋម។

## ៥.២- ការអប់រំនិងបណ្តុះបណ្តាល ៖

៥.២.១- អនុវត្តកម្មវិធីបណ្តុះបណ្តាលបន្តវេជ្ជសាស្ត្របុរាណតាមស្ថាប័នរដ្ឋ ឬ ស្ថាប័នឯកជនដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាល។

៥.២.២- រៀបចំនិងជំរុញការបណ្តុះបណ្តាលវេជ្ជសាស្ត្របុរាណក្នុងប្រព័ន្ធរៀបរយអាកាដេមិកដូចដែលប្រទេសជាច្រើនក្នុងតំបន់បាននិងកំពុងអនុវត្ត។

៥.២.៣- ធ្វើឲ្យប្រសើរឡើងនូវកិច្ចសហការគ្នារវាងវេជ្ជសាស្ត្របុរាណ និងសម័យនៅតាមសេវាសុខភាពសាធារណៈ ។

៥.២.៤- អប់រំឱ្យប្រជាពលរដ្ឋចេះដាំដុះថែរក្សានិងប្រើប្រាស់ឱសថរុក្ខជាតិ និងចែកចាយព័ត៌មានឱសថបុរាណឲ្យបានទូលំទូលាយ។

## ៥.៣- វត្ថុធាតុដើមនិងផលិតផល

៥.៣.១- អភិរក្សនិងអភិវឌ្ឍរុក្ខជាតិ និងជីវៈចម្រុះដើម្បីធានានិរន្តរភាពនៃការប្រមូលផលការផ្គត់ផ្គង់វត្ថុធាតុដើមបម្រើឲ្យវេជ្ជសាស្ត្របុរាណតាមរយៈការអប់រំប្រជាពលរដ្ឋ សិស្សសាលាឲ្យចេះការពារ និងដាំដុះតាមសហគមន៍បង្កើតសួនឱសថរុក្ខជាតិ និងកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងការរក្សាធនធាន ធម្មជាតិ និងជីវៈចម្រុះក្នុងស្រុកដែលមានប្រយោជន៍ដល់ឱសថបុរាណ។

៥.៣.២- រៀបចំកម្មវិធីសិក្សាស្រាវជ្រាវម៉ូណូក្រាហ្វ(monograph)នៃរុក្ខជាតិនិមួយៗ ដោយធ្វើបច្ចុប្បន្នភាព និងបន្តធ្វើបន្ថែមលើរុក្ខជាតិទាំងឡាយដែលមាននៅក្នុងប្រទេស ដើម្បីឆ្ពោះទៅកសាងសៀវភៅក្បួនរុក្ខជាតិឱសថ ( pharmacopeia of medicinal plants ) សម្រាប់ព្រះរាជាណាចក្រកម្ពុជា។

៥.៣.៣- ផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រទំនើបដើម្បីធ្វើឱ្យផលិតផលឱសថបុរាណមានគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាព។

៥.៣.៤- យកចិត្តទុកដាក់បន្ថែមលើយន្តការចុះបញ្ជិកាឱសថបុរាណ ដើម្បីកាត់បន្ថយ និងឈានទៅលុបបំបាត់ការផលិត ការនាំចូល និងការចែកចាយឱសថបុរាណខុសច្បាប់។

៥.៣.៥- យកចិត្តទុកដាក់ក្នុងការបង្កើតបញ្ជីឱសថបុរាណមួយចំនួន ដើម្បីបញ្ចូលក្នុងបញ្ជីឱសថសារវ័ន្តជាតិ និងការផលិតឃីតឱសថបុរាណបែបងាយៗចែកជូនមណ្ឌលសុខភាពនិងសហគមន៍។

## ៥.៤- ការសិក្សាស្រាវជ្រាវ

៥.៤.១-ត្រូវសំអាងលើការសិក្សាពិសោធន៍ដែលមានលក្ខខណ្ឌគ្លីនីក លក្ខខណ្ឌមន្ទីរពិសោធន៍ និងលក្ខខណ្ឌនៃការផលិត ដោយផ្អែកលើនិយាមនិងមគ្គុទ្ទេសឱសថបុរាណ ដែលកំណត់ដោយអង្គការអន្តរជាតិ ដូចជាអង្គការសុខភាពពិភពលោក អាស៊ាន និងសហគមអឺរ៉ុប។

៥.៤.២- បណ្តុះបណ្តាលធនធានមនុស្សលើផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍វេជ្ជសាស្ត្របុរាណ។

៥.៤.៣- យកចិត្តទុកដាក់លើបញ្ហាទាក់ទងនឹងកម្មសិទ្ធិបញ្ញា។

### ៥.៥- សហប្រតិបត្តិការជាតិនិងអន្តរជាតិ

សហការជាមួយអង្គការក្នុងស្រុកពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ដើម្បីចែករំលែកព័ត៌មានបទពិសោធន៍ជាប្រយោជន៍ដល់ដំណើរការអប់រំបណ្ដុះបណ្ដាលការស្រាវជ្រាវ និងការអភិវឌ្ឍវេជ្ជសាស្ត្របុរាណ។

### ៥.៦- ការត្រួតពិនិត្យនិងវាយតម្លៃ

៥.៦.១-បង្កើតកាលវិភាគនិងយន្តការសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃលើរាល់ការអនុវត្តគោលនយោបាយនេះ និងវិធានការណ៍កែលម្អសម្រាប់អនាគត។

៥.៦.២-បង្កើតទិន្នន័យសម្រាប់កត់សម្គាល់លើសកម្មភាពការគ្រប់គ្រង និងការអភិវឌ្ឍវេជ្ជសាស្ត្របុរាណ។

៥.៦.៣- ប្រើប្រាស់លទ្ធផលនៃការត្រួតពិនិត្យ ដើម្បីវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ និងធ្វើការកែលំអបន្ថែមទៀតក្នុងករណីចាំបាច់៕

Kingdom of Cambodia
Nation Religion King

# Traditional Medicine Policy of the Kingdom of Cambodia

Ministry of Health

Supported by WHO

# Traditional Medicine Policy of the Kingdom of Cambodia 2010

## Content

**1.INTRODUCTION**......2
**2. DEFINITION**......2

*2.1 Traditional Medicine*......2

*2.2 Traditional Medicine Products*......2

**3. POLICY STATEMENT ON TRADITIONAL MEDICINE**......3
**4. VISION, MISSION AND OBJECTIVES OF THE TRADITIONAL MEDICINE POLICY**...3

*4.1 Vision*......3
*4.2 Mission*......3
*4.3 Objectives*......3

**5. STRATEGIES OF THE TRADITIONAL MEDICINE POLICY**......4

*5.1 - Traditional Medicine Profession:*......4
*5.2 - Education and Training:*......4
*5.3 - Raw Materials and Products*......4
*5.4 - Research*......5
*5.5 - National and International Cooperation*......5
*5.6 Monitoring and Evaluation*......5

## 1. INTRODUCTION

Traditional Medicine Policy of the Kingdom of Cambodia is to be used as a reference guide for the implementation and management of Traditional Medicine in the Kingdom of Cambodia. This Policy covers the practice of Traditional Medicine, training and education, regulation, research and national and international cooperation in Traditional Medicine.

Traditional Medicine in the Kingdom of Cambodia provides a rich source of oral or written medical knowledge. Though little is known of the origins of Traditional Medicine, there is evidence to suggest that indigenous Khmer medicine developed during the Angkor period (9 to 15 century AD). These origins were adapted to local beliefs to create a traditional medical system in the region. The opportunity exists to use this knowledge better for primary health care and to improve accessibility to safe and effective treatment.

Traditional Medicine forms an important part in prevention, promotion, and treatment aspects of health care in the Kingdom of Cambodia. Because of its long history, many of the population are attached to their own folklore and rely on traditional methods to meet their health care needs. This is especially the case for people who live in rural and remote areas who use medicines available in the localities for the prevention or cure of common diseases, disorders and conditions. The rich tropical biodiversity of Kingdom of Cambodia is a valuable source for natural health products and the Royal Government will promote its full potential.

The Royal Government of the Kingdom of Cambodia will support Traditional Medicine, identify mechanisms to implement the policy with periodical evaluation and integrate traditional medicine into the national health system.

## 2. DEFINITION

### 2.1 Traditional Medicine

Traditional medicine is the sum total of knowledge, skills and practices on holistic health care, which is recognized and accepted by the community for its role in the maintenance of health and the treatment of diseases. Traditional medicine is based on theory, beliefs and experiences that are indigenous to different cultures, and that is developed and handed down from generation to generation.

### 2.2 Traditional Medicine Products

Traditional Medicine products are products derived from plant, animal or mineral material with health benefits that contain either single or combined raw or processed ingredients. This definition excludes materials where the active component has been isolated or synthesised or the processing is not consistent with the traditional paradigm.

## 3. POLICY STATEMENT ON TRADITIONAL MEDICINE

Traditional Medicine shall be an important component of the healthcare system in the Kingdom of Cambodia. It will co-exist with modern medicine and contribute towards enhancing the living conditions of all Cambodians.

The Royal Government of the Kingdom of Cambodia will facilitate the implementation of this Traditional Medicine Policy and will put in place provisions that would promote the quality, safety and effectiveness of Traditional Medicine practices and products. The Traditional Medicine Policy together with the Medicines Policy of the Kingdom of Cambodia aims to complement the needs in the communities in terms of disease prevention and treatment based on evidence.

## 4. VISION, MISSION AND OBJECTIVES OF THE TRADITIONAL MEDICINE POLICY

### 4.1 Vision

To help maintain and improve the health of all the people of the Kingdom of Cambodia, with a focus on remote areas and the poorer segment of the population, through access to and rational use of affordable, quality, safe and effective Traditional Medicine practices and products.

### 4.2 Mission

To ensure that quality, safe and effective Traditional Medicine practices and products are made available to the people through the nation's health care system.

### 4.3 Objectives

Traditional Medicine Policy has the following objectives:

4.3.1 - Promote traditional medicine profession for the benefits of the health sector, society and economy as a whole by putting emphasis on:

- Development of additional legislations, provisions and code of ethics
- Rational use of traditional medicine
- Integration of traditional medicine into the national health care system

4.3.2 - Implement formal and non-formal trainings to respond to the progress made in the country as well as in the region.

4.3.3 - Pay attention to raw materials and products:

- Conserve and develop natural resources and biodiversities in the country to ensure potential and sustainability of the needs for raw materials and traditional medicine products;
- Regulate the production and distribution of traditional medicine products to ensure quality, effectiveness and safety according to the standards and based on scientific basis.

4.3.4 - Support and motivate research, information dissemination and national and international cooperation.

4.3.5 - Undertake periodical monitoring and evaluation of the implementation of this policy.

## 5. STRATEGIES OF THE TRADITIONAL MEDICINE POLICY

To achieve the above objectives, the following strategies are put in place:

### 5.1 - Traditional Medicine Profession:

5.1.1 - Develop regulations governing traditional medicine service and business registration and raw materials, semi-processed products and finished products of traditional medicine;

5.1.2 - Develop traditional medicine profession through training with permission from the Ministry of Health;

5.1.3 - Manage the statistics of traditional medicine service providers and products sellers of any kinds;

5.1.4 - Association of traditional medicine practitioners and organizations working in traditional medicine and traditional medicine products shall place attention on the requirements and qualification of their members, enforce laws, regulations and code of conduct against fraudulent activities, which harm the health and life of citizens;

5.1.5 - Identify ways to integrate traditional medicine into the primary health care system.

### 5.2 - Education and Training:

5.2.1 - Implement continuing training programs on traditional medicine in state or private organizations with accreditation from the Ministry of Health;

5.2.2 - Prepare and promote traditional medicine training in the formal academic system as having been done in many countries in the region;

5.2.3 - Improve cooperation between traditional and modern medicines in public health services;

5.2.4 - Educate citizens to cultivate, maintain and use medicinal plants and disseminate information on traditional medicines broadly;

### 5.3 - Raw Materials and Products

5.3.1 - Conserve and develop plants and biodiversity to ensure sustainable harvest and raw material supply for traditional medicines by educating people and students to protect and cultivate medicinal plants in their community and create botanical gardens and cooperating with relevant authorities to

protect local natural resources and biodiversities which are beneficial for traditional medicine products;

5.3.2 - Set up programs to research monographs on each plants by updating and expanding monographs on all local plants towards the production of a pharmacopoeia of medicinal plants for the Kingdom of Cambodia;

5.3.3 - Ensure quality, efficacy and safety of traditional medicine products based on scientific evidence;

5.3.4 - Pay additional attention on the registration of traditional medicine products in order to reduce and eliminate the production, importation and distribution of illicit traditional medicine products;

5.3.5 - Pay attention on the establishment of a registry of some traditional medicine products to include in the national registry of essential drugs and on the production of basic traditional medicine product kits to be distributed to health centers and communities.

### 5.4 - Research

5.4.1 - Approach to research including laboratory, clinical and manufacture research shall be adopted based on the standards and guides on traditional medicine products of international organizations such World Health Organization, ASEAN and European Union;

5.4.2 - Provide trainings on traditional medicine research and development;

5.4.3 - Pay attention on issues related to intellectual property rights;

### 5.5 - National and International Cooperation

Cooperate with local organizations and strengthen and expand national and international cooperation to share information and experiences for the benefits of education, training, research and development of traditional medicines.

### 5.6 Monitoring and Evaluation

5.6.1 - Create a timeline and mechanism for monitoring and evaluating the implementation of this policy and improvement measures for the future;

5.6.2 - Create database for recording management activities and development of traditional medicine;

5.6.3 - Use the results of the monitoring to evaluate the effectiveness of the policy implementation and make necessary improvements.